# ក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វ្យ៉ា
# ការិយាល័យទំនាក់ទំនងជាមួយ ក្រុមគ្រួសារ និង សហគមន៍


440 N. BROAD STREET, SUITE 114
PHILADELPHIA, PENNSYLVANIA 19130

**EVELYN SAMPLE-OATES** — ទូរស័ព្ទ (២១៥) ៤០០-៤១៨០

នាយិកា — ទូរសារ (២១៥) ៤០០-៤១៨១


ជូនចំពោះ មាតាបិតា និងអាណាព្យាបាល៖

យើងខ្ញុំដឹងថា សិស្សានុសិស្ស និងក្រុមគ្រួសាររបស់ពួកគេជាច្រើន ពឹងផ្អែកទៅលើអ៊ិនធ័រណិត ទោះជានៅសាលា ឬនៅផ្ទះក្តី ដើម្បីពួកគេអាចធ្វើកិច្ចការដែលគ្រូដាក់ឲ្យធ្វើនៅផ្ទះ ស្វែងរកការងារ រកមើលប្រាក់ជំនួយ ឬការបម្រើរបស់រដ្ឋាភិបាល និងអ្វីៗជាច្រើនទៀត។ ក្នុងនាមជាអ្នកអប់រំ នាងខ្ញុំដឹងថា ការមានអ៊ិនធ័រណិតនៅផ្ទះគឺជាការសំខាន់ណាស់ ដើម្បីធ្វើយ៉ាងណាឲ្យកូនរបស់លោកអ្នកអាចទាក់ទងជាមួយ កិច្ចការដែលគ្រូដាក់ឲ្យធ្វើ មិត្តរួមថ្នាក់ និងគ្រូ តាមអ៊ិនធ័រណិត។ ដោយមូលហេតុនេះហើយបានជាយើងខ្ញុំចង់ធ្វើយ៉ាងណាឲ្យលោកអ្នកដឹងអំពីអ៊ិនធ័រណិតនៅផ្ទះដែលមានតម្លៃថោក ហៅថា អ៊ិនធ័រណិត អេស្សិនទ្យាល្ស (Internet Essentials SM) ពីក្រុមហ៊ុន ខំខាស្ត (Comcast)។

- លក្ខណៈពិសេសនៃ Internet Essentials រួមមាន៖
- ៩,៩៥$ ក្នុងមួយខែ បូកថ្លៃពន្ធ ដោយគ្មានកិច្ចសន្យាលើកំណត់ពេល ឬពិនិត្យមើលទំនុកទុកចិត្តផ្នែកឥណទាន (credit checks)
- ឥតបង់ថ្លៃសម្រាប់ ការបើកកម្មវិធី ឬឧបករណ៍
- ផ្តល់ឲ្យ WiFi router
- អាចទិញ កុំព្យូទ័រលើតុ ឬកុំព្យូទ័រយួរដៃ ត្រឹមតែ ១៤៩,៩៩$
- រៀនប្រើអ៊ិនធ័រណិត ក្នុងថ្នាក់ផ្ទាល់ ឬរៀនតាមអ៊ិនធ័រណិត ដោយឥតគិតថ្លៃ

ឥឡូវនេះមានព័ត៌មានល្អបំផុត។ កាន់តែមានការងាយស្រួល និងកាន់តែលឿន ចំពោះក្រុមគ្រួសាររបស់លោកអ្នកក្នុងការតភ្ជាប់ទៅ Internet Essentials ដោយសារសាលាជាច្រើននៅក្នុងទីក្រុងហ្វីឡាដែលហ្វ្យ៉ាមានការយល់ព្រមជាមុនសម្រាប់ការចុះឈ្មោះ។ សូមទូរស័ព្ទមកលេខ ១-៨៥៥-៨៤៦-៨៣៧៦ ឬដាក់ពាក្យស្នើសុំតាមអ៊ិនធ័រណិត InternetEssentials.com។ លោកអ្នកត្រូវផ្តល់ព័ត៌មានសម្រាប់ទាក់ទង និងឈ្មោះសាលារបស់លោកអ្នក តែប៉ុណ្ណោះ គេមិនត្រូវការក្រដាសស្នាមអ្វីទៀតទេ ហើយបើសិនជាលោកអ្នកត្រូវតាមលក្ខណៈវិនិច្ឆ័យនៃការចូលរួមក្នុងកម្មវិធីនេះ គេនឹងយល់ព្រមជាមួយលោកអ្នកជាមុន ហើយលោកអ្នកអាចមានអ៊ិនធ័រណិតនៅផ្ទះក្នុងកំឡុងពេល ៥ ថ្ងៃ។

យើងខ្ញុំចង់ឲ្យសិស្សានុសិស្សរបស់យើងទាំងអស់មានឱកាសធ្វើកិច្ចការដែលគ្រូដាក់ឲ្យធ្វើនៅផ្ទះ ហើយយើងខ្ញុំមានក្តីរំភើបដើម្បីជម្រាបលោកអ្នកអំពីកម្មវិធីផ្សេងៗ ដូចជាកម្មវិធី Internet Essentials ពីក្រុមហ៊ុន Comcast ដែលអាចជួយដល់ក្រុមគ្រួសាររបស់លោកអ្នក។

ដោយសេចក្តីស្មោះស្ម័គ្រ

*Karen L. James*

Karen L. James
ប្រធាន ការិយាល័យ ទំនាក់ទំនងជាមួយ ក្រុមគ្រួសារ និង សហគមន៍